HANSOLL

Tailoring to Your Comfort

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀងរវាង

# រោងចក្រ ខេមបូ យូនីសូល អិលធីឌី ជាមួយនឹងកម្មករ-និយោជិត

យោងតាមស្ថានភាពរោងចក្រនាពេលបច្ចុប្បន្ន មានបញ្ហាខ្វះការបញ្ជាទិញ បានធ្វើឲ្យប៉ះពាល់ពាល់ដល់ខ្សែសង្វាក់ផលិតកម្ម ហេតុដូចនេះ រោងចក្របានទទួលការឯកភាពពីកម្មករ-និយោជិតទាំងអស់ដែលតំណាងដោយសហជីព និងប្រតិភូបុគ្គលិកដូចខាងក្រោម៖

១- កម្មករ-និយោជិតចំនួន ១៧២១នាក់ (ស្រីចំនួន ១៥៨៣នាក់) ក្នុងចំណោមកម្មករ-និយោជិតសរុបចំនួន ១៨៩៩នាក់ ត្រូវព្យួរកិច្ចសន្យាការងារចាប់ពីថ្ងៃ ១៦ ខែមិថុនា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០២៣។ អំឡុងពេលព្យួរកិច្ចសន្យាការងារនេះ រោងចក្រនឹងផ្តល់អត្ថប្រយោជន៍ស្របតាមសេចក្តីណែនាំលេខ០២០/២៣ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កម្មករ-និយោជិតម្នាក់ៗនឹងទទួលបានផ្តល់ប្រាក់ឧបត្ថម្ភចំនួន ៣០ដុល្លារអាមេរិក ពីរោងចក្រ។

២- រោងចក្រនឹងបើកប្រាក់ឈ្នួលលើកទី១ នៃខែមិថុនា ជូនកម្មករ-និយោជិតនៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៣។

៣- រោងចក្រនឹងបើកប្រាក់ឈ្នួលលើកទី២ នៃខែមិថុនា រួមជាមួយនឹងប្រាក់ឧបត្ថម្ភអំឡុងពេលព្យួរការងារចំនួន ៣០ដុល្លារអាមេរិក ជូនកម្មករ-និយោជិតនៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣។

៤- កម្មករ-និយោជិតទាំងអស់ត្រូវត្រលប់ចូលធ្វើការងារវិញនៅថ្ងៃសៅរ៍ ទី០១ ខែកក្កដា ឆ្នាំ២០២៣ ចំពោះកម្មករ-និយោជិតណាដែលមិនត្រលប់មកធ្វើការងារតាមពេលវេលាកំណត់ រោងចក្រនឹងអនុវត្តន៍តាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ក៏ដូចជាបទបញ្ញត្តិ និងច្បាប់ស្តីពីការងារ។

**បញ្ជាក់៖** កិច្ចព្រមព្រៀងនេះមានប្រសិទ្ធិភាពចំពោះកម្មករ-និយោជិតទាំងអស់របស់រោងចក្រ ខេមបូ យូនីសូល អិលធីឌី ជាមួយនឹងនិយោជកនៃរោងចក្រ ខេមបូ យូនីសូល អិលធីឌី ចាប់ពីពេលចុះហត្ថលេខា នេះតទៅ។

ថ្ងៃសៅរ៍ ០៨កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ធ្វើនៅកណ្តាល ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៣

**ថ្នាក់ដឹកនាំសហជីព និងប្រតិភូបុគ្គលិក**

**អគ្គនាយកក្រុមហ៊ុន**

ព្រះរាជាណាចក្រកម្ពុជា ខេមបូ យូនីសូល អិលធីឌី CAMBO UNISOLL LTD. KINGDOM OF CAMBODIA

**កាង ម៉ូន សាន់**

Che Nen.